(12)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តក្រចេះ

សាលក្រម
នាងនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងខេត្តក្រចេះ

សំណុំរឿងរដ្ឋប្បវេណីលេខ: ៣៧
ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៩
ហាលក្រមរដ្ឋប្បវេណីលេខ: ៦៤-ង-
ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩
និងប្រកាសសាលក្រមជាសាធារណៈ នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩
ដោយមានសមាសភាពដូចតទៅ៖

ចៅក្រម

លោក **ញ៉ិល ឃុនលី** ចៅក្រមសាលាដំបូងខេត្តក្រចេះ ។

ក្រឡាបញ្ជី

លោក **សយ យ៉ាន់សន្តិរដ្ឋី** ក្រឡាបញ្ជីសាលាដំបូងខេត្តក្រចេះ ។

+រវាងសហជើមចោទ៖ ធនាគារ ដ ដែលមានអាសយដ្ឋាន ខេត្តក្រចេះ។

តំណាងដោយ៖

លោក ត១ ដ សញ្ជាតិខ្មែរ ។

លោក ត២ ដ សញ្ជាតិខ្មែរ ។

+និងសហចុងចម្លើយ៖

១.ឈ្មោះ ច១ ភេទប្រុស កើតថ្ងៃទី០៣ ខែឧសភា ឆ្នាំ១៩៩០ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ទីលំនៅបច្ចុប្បន្ននៅ ខេត្តក្រចេះ។

២.ឈ្មោះ ច២ ភេទប្រុស កើតថ្ងៃទី០១ ខែឧសភា ឆ្នាំ១៩៥៤ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ទីលំនៅបច្ចុប្បន្ននៅ ខេត្តក្រចេះ (ប្តី)។

៣.ឈ្មោះ ច៣ ភេទស្រី កើតថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៥៨ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ទីលំនៅបច្ចុប្បន្ននៅ ខេត្តក្រចេះ (ប្រពន្ធ)។

អ្នកតំណាងដោយអាណាត្តិរបស់សហចុងចុម្លើយ៖ លោកមេធាវី ជុន សុជាតិ មានការិយាល័យនៅអាគារលេខ ១៥ ផ្លូវ២៥៣ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

កម្មវត្ថុបណ្តឹង៖ ដើមចោទបានប្តឹងសុំឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារដូចខាងក្រោម៖

កំណត់សំគាល់៖ សាលក្រមនេះជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ

១.ប្រាក់ដើមចំនួន ៦៦,០៧៨.៥៨ (ហុកសិបប្រាំមួយពាន់ចិតសិបប្រាំបីដុល្លារអាមេរិក និងហាសិបប្រាំបីសេន)។

២.អត្រាការប្រាក់ចំនួន ១០.៥០% **ក្នុងមួយឆ្នាំ** លើប្រាក់ដើមដែលនៅជំពាក់ គិតចាប់ពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៨ រហូតដល់ថ្ងៃអនុវត្តការសងប្រាក់គ្រប់ចំនួន។

៣- អត្រាប្រាក់ពិន័យ (ប្រាក់សំណងការខូចខាតដោយសារការយឺតយ៉ាវ) ចំនួន ២៤% **ក្នុងមួយឆ្នាំ** លើចំនួនទឹកប្រាក់ដែលខកខានមិនបានសង សមាមាត្រ ទៅនឹង ចំនួនថ្ងៃដែលខកខានសង គិតចាប់ពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៨ រហូតដល់ថ្ងៃអនុវត្តការសងប្រាក់គ្រប់ ចំនួន ។

៤-សេវាពិគ្រោះផ្លូវច្បាប់ និងប្រាក់ដំងឺចិត្តចំនួន USD ៥,000.00 (ប្រាំពាន់ដុល្លារអាមេរិកគត់)។

៥-ចេញសាលក្រមដែលអាចយកទៅអនុវត្តជាបណ្តោះអាសន្នបាន ។

៦-បង្គាប់ឲ្យចុងចម្លើយជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្តី ។

អង្គហេតុ និងចំណុចវិនិច្ឆ័យ

ក/ អំពីអង្គហេតុ:

កាលពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៨ **ឈ្មោះ** ច១ បានចុះកិច្ចសន្យាខ្ចីប្រាក់ (ឥណទានអាជីវកម្មខ្នាតមធ្យម) លេខ: ពី **ធនាគារ** ជ **សាខាខេត្តក្រចេះ** ចំនួន USD ៦៧,000.00 (ហុកសិបប្រាំពីរពាន់ដុល្លារអាមេរិកគត់) រយៈពេល១២០ខែ ក្នុងអត្រាការប្រាក់ ១០.៥០%**ក្នុងមួយឆ្នាំ** ។ ដោយកូនបំណុលខាងលើបានដាក់ធានាអចលនវត្ថុ: ដីសាងសង់ និងផ្ទះថ្មប្រក់ស័ង្កសី ដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៨ មានទីតាំងស្ថិតនៅ ខេត្តក្រចេះ ចេញដោយ ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តក្រចេះ ដោយមានឈ្មោះ ច២ និង ច៣ ជាកម្មសិទ្ធិករ ។

គិតត្រឹមថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៩ **ឈ្មោះ** ច១ បានសងប្រាក់ដើមចំនួន USD ៩២១.៤២ (ប្រាំបួនរយម្ភៃមួយដុល្លារអាមេរិក និងសែសិបពីរសេន) និងបានបង់ការប្រាក់ចំនួន USD ២,៧២០.២៥ (ពីរពាន់ប្រាំពីររយម្ភៃដុល្លារអាមេរិក និងម្ភៃប្រាំសេន) តែប៉ុណ្ណោះ ។

គិតត្រឹមថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៩ ចុងចម្លើយខាងលើនៅជំពាក់ប្រាក់ធនាគារចំនួន:

-ប្រាក់ដើមចំនួន USD ៦៦,០៧៨.៥៨ (ហុកសិបប្រាំមួយពាន់ចិតសិបប្រាំបីដុល្លារអាមេរិក និងហាសិបប្រាំបី សេន) ។

-ការប្រាក់ចំនួន USD ១,៤២២.៥៦ (មួយពាន់បួនរយម្ភៃពីរដុល្លារអាមេរិក និងហាសិបប្រាំមួយសេន)

-ប្រាក់ពិន័យចំនួន USD ១០៩.៨១ (មួយរយប្រាំបួនដុល្លារអាមេរិក និងប៉ែតសិបមួយសេន)។

+ សរុបបំណុលដែលនៅជំពាក់មានចំនួន USD ៦៧,៦១០.៩៥ (ហុកសិបប្រាំពីរពាន់ប្រាំមួយរយ ដប់ដុល្លារអាមេរិក និងកៅសិបប្រាំសេន) ។

ខ/ អង្គហេតុដែលគ្មានវិនិច្ឆ័យ:

- មេធាវីតំណាងដោយអាណត្តិរបស់សហចុងចម្លើយបានថ្លែងការណ៍ថា: ខ្ញុំបានទទួលស្គាល់ការទាមទារប្រាក់ដើមចំនួន ៦៦,០៧៨.៥៨ (ហុកសិបប្រាំមួយពាន់ ចិតសិបប្រាំបីដុល្លារអាមេរិក និងហាសិបប្រាំបីសេន)។

កំណត់សំគាល់: សាលក្រមនេះជារឿងក្តីដាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ

គ/ ចំណុចវិវាទ៖

១/ តើការទាមទារ ការប្រាក់ចំនួន ១០.៥០% **ក្នុងមួយឆ្នាំ** លើប្រាក់ដើមដែលនៅជំពាក់ គិតចាប់ពីថ្ងៃទី ១៧ ខែតុលា ឆ្នាំ២០១៨ រហូតដល់ថ្ងៃអនុវត្តការសងប្រាក់គ្រប់ចំនួន របស់ដើមចោទ ជាការត្រឹមត្រូវ និងស្រប តាមច្បាប់ដែរឬទេ?

២/ តើការទាមទារ អត្រាប្រាក់ពិន័យចំនួន ២៤% **ក្នុងមួយឆ្នាំ** លើចំនួនទឹកប្រាក់ដែលខកខានមិនបានសង សមាមាត្រ ទៅនឹងចំនួនថ្ងៃដែលខកខានសង គិតចាប់ពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៨ រហូតដល់ថ្ងៃអនុវត្តការសង ប្រាក់គ្រប់ចំនួន របស់ដើមចោទ ជាការត្រឹមត្រូវ និងស្របតាមច្បាប់ដែរឬទេ?

ការអះអាងរបស់ភាគីពីចំណុចវិវាទ៖

ក/ ចំណុចវិវាទទី១៖

១/ ភាគីដើមចោទ៖

ចាប់ពីថ្ងៃខ្ចីប្រាក់រហូតមកដល់បច្ចុប្បន្នសហចុងចម្លើយឈ្មោះ ច១ ឈ្មោះ ច២ ឈ្មោះ ច៣ នៅជំពាក់ប្រាក់ដើមសរុបចំនួន ៦៦,០៧៨.៥៨ (ហុកសិបប្រាំមួយពាន់ចិតសិបប្រាំបីដុល្លារអា មេរិក និងហាសិបប្រាំបីសេន) រួមទាំង ការប្រាក់ ១០.៥០% **ក្នុងមួយឆ្នាំ** គិតចាប់ពី ថ្ងៃទី១៧ ខែតុលា ឆ្នាំ ២០១៨ លើប្រាក់ដើមចំនួន ៦៦,០៧៨.៥៨ (ហុកសិបប្រាំមួយពាន់ចិតសិបប្រាំបីដុល្លារអាមេរិក និងហាសិប ប្រាំបីសេន) និង ប្រាក់ពិន័យ ២៤% **ក្នុងមួយឆ្នាំ** គិតចាប់ពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ ២០១៨ លើប្រាក់ដើមចំនួន ៦៦,០៧៨.៥៨ (ហុកសិបប្រាំ មួយពាន់ចិត សិបប្រាំបីដុល្លារអា មេរិក និងហាសិបប្រាំបីសេន)។

ហេតុដូច្នេះ យោងតាមកិច្ចសន្យាចងការប្រាក់ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៨ ដែលធ្វើឡើងរវាងដើម ចោទ និងសហចុងចម្លើយ ត្រង់ប្រការ ៣ បញ្ញត្តិទាក់ទងនឹងការមិនបំពេញកាតព្វកិច្ច ចែងថា *"លក្ខខណ្ឌពិសេស៖* ៣.១ កថាខណ្ឌទី២ ភាគីម្ចាស់បំណុល នឹងអនុវត្តគ្រប់ពេលបន្ទាប់ពីការមិនគោរពតាមកិច្ចសន្យាដូចមានចែង ក្នុងលក្ខខណ្ឌទាំងឡាយនៃប្រការ១ (**អំពីលក្ខខណ្ឌទូរទៅ**) និងប្រការ២ (**អំពីលក្ខខណ្ឌរួម**) និងការកើតឡើង នៃការខកខានមិនបានសងប្រាក់។

២/ ភាគីចុងចម្លើយ៖

មេធាវីតំណាងដោយអាណត្តិរបស់សហចុងចម្លើយ បានថ្លែងការណ៍ថា៖ ខ្ញុំបាទទទួលស្គាល់ប្រាក់ដើម ចំនួន ៦៦,០៧៨.៥៨ (ហុកសិបប្រាំមួយពាន់ចិតសិបប្រាំបីដុល្លារអាមេរិក និងហាសិបប្រាំបីសេន) និងសុំប្រាន ចោលការទាម អត្រាការប្រាក់ចំនួន ១០.៥០% **ក្នុងមួយឆ្នាំ** លើប្រាក់ដើមដែលជំពាក់ ។

ខ/ ចំណុចវិវាទទី២៖

១/ ភាគីដើមចោទ៖

ចាប់ពីថ្ងៃខ្ចីប្រាក់រហូតមកដល់បច្ចុប្បន្នសហចុងចម្លើយឈ្មោះ ច១ ឈ្មោះ ច២ ឈ្មោះ ច៣ នៅជំពាក់ប្រាក់ដើមសរុបចំនួន ៦៦,០៧៨.៥៨ (ហុកសិបប្រាំមួយពាន់ចិតសិបប្រាំបីដុល្លារអា មេរិក និងហាសិបប្រាំបីសេន) រួមទាំងការប្រាក់ ១០.៥០% **ក្នុងមួយឆ្នាំ** គិតចាប់ពី ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៨ លើប្រាក់ដើមចំនួន ៦៦,០៧៨.៥៨ (ហុកសិបប្រាំមួយពាន់ចិតសិបប្រាំបីដុល្លារអាមេរិក និងហាសិប ប្រាំបីសេន) និង ប្រាក់ពិន័យ ២៤% **ក្នុងមួយឆ្នាំ** គិតចាប់ពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ ២០១៨ លើប្រាក់ដើមចំនួន ៦៦,០៧៨.៥៨ (ហុកសិបប្រាំ មួយពាន់ចិត សិបប្រាំបីដុល្លារអា មេរិក និងហាសិបប្រាំបីសេន)។

កំណត់សំគាល់៖ សាលក្រមនេះជារឿងក្តីដាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ

ចំណុច ៣.៥ ក្នុងករណីភាគី (កូនបំណុល) យឺតយ៉ាវមិនបានសងប្រាក់ទាន់ពេល វេលាតាមតារាងកាលវិភាគសងប្រាក់ ភាគី (កូនបំណុល) សុខចិត្តបង់ប្រាក់ពិន័យ អត្រាពិន័យត្រូវបានគិតស្មើរ នឹង **២៤%** (ម្ភៃបួនភាគរយ) **ក្នុងមួយឆ្នាំ** លើចំនួនទឹកប្រាក់ដែលខកខានមិនបានសង សមាមាត្រទៅនឹងចំនួនថ្ងៃដែលខកខានសង គិតចាប់ពីថ្ងៃទី០៤ (បួន) ហើយយល់ព្រមបង់ដោយផ្ទាល់ ឬ យល់ព្រមអោយកាត់យកជាស្វ័យប្រវត្តិពីគណនីរបស់ភាគី (កូនបំណុល)។

<u>២/ ភាគីចុងចម្លើយ៖</u>

មេធាវីតំណាងដោយអាណត្តិរបស់សហចុងចម្លើយ បានថ្លែងការណ៍ថា៖ ខ្ញុំបាទទទួលស្គាល់ប្រាក់ដើមចំនួន ៦៦,០៧៨.៥៨ (ហុកសិបប្រាំមួយពាន់ ចិតសិបប្រាំបីដុល្លារអាមេរិក និងហាសិបប្រាំបីសេន) និងសុំច្រានចោល អត្រាប្រាក់រំលែយចំនួន ២៤% ក្នុងមួយឆ្នាំ ។

អំពីឯកសារភស្តុតាង៖

១.ពាក្យបណ្តឹងសុំរបស់ធនាគារ ជ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៩។

២.លិខិតប្រគល់សិទ្ធរបស់ធនាគារ ជ ចុះថ្ងៃ ទី២៥ ខែកុម្ភៈ ឆ្នាំ២០១៨។

៣.កិច្ចសន្យាខ្ចីប្រាក់លេខ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៨(ជា ច្បាប់ថត ចម្លង)។

៤.កិច្ចសន្យាបង្កើតហ៊ីប៉ូតែក ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៨(ជា ច្បាប់ថតចម្លង)។

៥.តារាងកាលវិភាគប្រាក់ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ (ជាច្បាប់ថតចម្លង ១ច្បាប់)។

៦.តារាងសង្ខេបចំនួនទឹកប្រាក់ដែលនៅជំពាក់ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៩។

៧.ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០ ១៨ (ជាច្បាប់ចម្លង)។

៨.សៀវភៅគ្រួសារលេខ (ជាច្បាប់ចម្លង)។

៩.អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០ ១៦ របស់ឈ្មោះ ច១ (ជាច្បាប់ថតចម្លង)។

១០.អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០២ របស់ឈ្មោះ ច២ (ជាច្បាប់ថតចម្លង)។

១១.អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០២ របស់ឈ្មោះ ច៣ (ជាច្បាប់ថតចម្លង)។

១២.លិខិតបញ្ជាក់ទីលំនៅលេខ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៨ របស់ ឈ្មោះ ច២ និង ឈ្មោះ ច៣ (ជាច្បាប់ថតចម្លង)។

១៣.លិខិតបញ្ជាក់ទីលំនៅលេខ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៨ របស់ ឈ្មោះ ច១ (ជាច្បាប់ថតចម្លង)។

<u>សំអាងហេតុ</u>

១/ តាមសេចក្តីថ្លែងការណ៍ទទួលស្គាល់អង្គហេតុប្រាក់ដើមរបស់ភាគីដើមចោទ និងពិនិត្យភស្តុតាងជាឯកសាររួមមាន៖ កិច្ចសន្យាខ្ចីប្រាក់ លេខ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៨, កិច្ចសន្យាបង្កើតហ៊ីប៉ូតែក ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៨, តារាងកាលវិភាគប្រាក់ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨

កំណត់សំគាល់៖ សាលក្រមនេះជារឿងក្តីដាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ

និងតារាងសង្ខេបចំនួនទឹកប្រាក់ដែលនៅជំពាក់ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៩ បញ្ជាក់ឱ្យឃើញថាចុងចម្លើយពិតជាបានបង្កើតកិច្ចសន្យាខ្ចីប្រាក់ ព្រមទាំងបានទទួលនូវប្រាក់កម្ចីពីដើមចោទ ប្រាកដមែន ។ ដែលបានធ្វើឡើងដោយកំណត់អត្រាការប្រាក់ និងប្រាក់ពិន័យ ជាលាយល័ក្ខណ៍អក្សរច្បាស់លាស់ និងត្រឹមត្រូវតាមច្បាប់ ស្របតាមបញ្ញត្តិមាត្រា **៥៧៩** (ការបង្កើតកិច្ចសន្យាខ្ចីបរិភោគ) និងមាត្រា **៥៨៣** (សិទ្ធិលើបំណុល ដែលជាការប្រាក់) នៃក្រមរដ្ឋប្បវេណី ។

២/ យោងតាមសេចក្តីថ្លែងការរបស់មេធាវីសហចុងចម្លើយ នាកាលបរិច្ឆេទនៃនីតិវិធីទាញហេតុផលផ្ទាល់មាត់ថា ខ្លួនទទួលស្គាល់ការទាមទារប្រាក់ដើមដែលនៅជំពាក់ធនាគារ **ចំនួន ៦៦,០៧៨.៥៨** (ហុកសិបប្រាំមួយពាន់ ចិតសិបប្រាំបី ដុល្លារអាមេរិក និងហាសិបប្រាំបីសេន) ។ ហេតុដូច្នេះគប្បីតុលាការទទួលស្គាល់នូវអង្គហេតុ និងចំនួននៃទឹកប្រាក់ដើមជំពាក់នេះ ដោយពុំចាំបាច់ពិនិត្យលើកស្តុតាង ស្របតាមមាត្រា **១២៣** កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

៣/ មេធាវីរបស់សហចុងចម្លើយបានធ្វើសេចក្តីថ្លែងការណ៍បន្តទៀតថា៖ ការទាមទារក្រៅពីនេះ (ប្រាក់ដើម) ខ្លួនសុំច្រានចោល (ការប្រាក់ និងប្រាក់ពិន័យ) ។

ការមិនទទួលស្គាល់អង្គហេតុ និងការសុំច្រានចោទ លើចំណុចការទាមទារ **ការប្រាក់ ១០.៥០% ក្នុងមួយឆ្នាំ** គិតចាប់ពី ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៨ លើប្រាក់ ដើមចំនួន **៦៦,០៧៨.៥៨** (ហុកសិបប្រាំមួយពាន់ចិតសិបប្រាំបីដុល្លារអាមេរិក និងហាសិបប្រាំបីសេន) និង **ប្រាក់ពិន័យ** (ប្រាក់សំណងការខូចខាតដោយសារការយឺតយ៉ាវ) **២៤% ក្នុងមួយឆ្នាំ** គិតចាប់ពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ ២០១៨ លើប្រាក់ដើមចំនួន **៦៦,០៧៨.៥៨** (ហុកសិបប្រាំ មួយពាន់ចិត សិបប្រាំបីដុល្លារអាមេរិក និងហាសិបប្រាំបីសេន) របស់មេធាវីសហចុងចម្លើយគឺមិនបង្ហាញនូវអង្គហេតុនៃការតវ៉ានេះ ក៏ដូចជាមិនបានបង្ហាញពីឯកសារកស្តុតាងផ្សេងៗដែលបញ្ជាក់នូវការច្រានចោលការទាមទាររបស់ដើមចោទ ឲ្យតុលាការបានពិនិត្យ និងពិចារណាបានទេ ពោលគឺ មេធាវីរបស់សហចុងចម្លើយបានត្រឹមតែធ្វើសេចក្តីថ្លែងការណ៍មួយឃ្លាថា "ការទាមទារក្រៅពីនេះ (ប្រាក់ដើម) ខ្លួនសុំច្រានចោល (ការប្រាក់ និងប្រាក់ពិន័យ)" ។

៤/ ភាគីដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ និងបង្ហាញកស្តុតាងដើម្បីបញ្ជាក់នូវការទាមទាររបស់ខ្លួនលើ **ការប្រាក់ចំនួន ១០.៥០% ក្នុងមួយឆ្នាំ** គិតចាប់ពី ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៨ លើប្រាក់ ដើមចំនួន **៦៦,០៧៨.៥៨** និង **ប្រាក់ពិន័យ** (ប្រាក់សំណងការខូចខាតដោយសារការយឺតយ៉ាវ) **២៤% ក្នុងមួយឆ្នាំ** គិតចាប់ពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ ២០១៨ លើប្រាក់ដើមចំនួន **៦៦,០៧៨.៥៨** ដូចតទៅ៖

តាមកិច្ចសន្យាខ្ចីប្រាក់លេខ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៨ ចុងចម្លើយបានបង្កើតកិច្ចសន្យាខ្ចីប្រាក់ ដោយមានប្រាក់ដើមសរុប **ចំនួន ៦៦,០៧៨.៥៨** (ត្រែទី១ ចំណុច ១.១ នៃប្រការ១) ។

ត្រែទី៦ ចំណុច ១.១ នៃប្រការ១៖ គូភាគីបានកំណត់ និងព្រមព្រៀង ការប្រាក់ចំនួន **១០.៥០% ក្នុងមួយឆ្នាំ** គិតចាប់ពី ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៨ លើប្រាក់ដើម ។

ចំណុច ៣.៥ នៃប្រការ៣៖ គូភាគីបានកំណត់ និងព្រមព្រៀង **ប្រាក់ពិន័យ** (ប្រាក់សំណងការខូចខាតដោយសារការយឺតយ៉ាវ) ចំនួន **២៤% ក្នុងមួយឆ្នាំ** គិតចាប់ពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ ២០១៨ លើប្រាក់ដើម ។

៥/ ចំពោះការទាមទារការប្រាក់ ១០.៥០% ភាគរយក្នុងមួយឆ្នាំ របស់ដើមចោទ គឺមានភាពត្រឹមត្រូវតាមច្បាប់ និងអាចទទួលយកបាន ។ យោងមាត្រា៥៨៥ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី បានចែងថា "*អត្រាការ*

កំណត់សំគាល់៖ សាលក្រមនេះជារឿងក្តីដាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ

ប្រាក់ដែលត្រូវបានកម្រិត សំដៅទៅលើអត្រាការប្រាក់អតិបរមាដែលអាចកំណត់បានដោយស្របច្បាប់ តាមការព្រមព្រៀងរបស់ភាគី ដែលបានកំណត់ដោយច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀត" ។

យោងមាត្រា១៧ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី បានចែងថា *"អត្រាការប្រាក់ដែលត្រូវបានកម្រិត ដែលកំណត់ក្នុងកថាខណ្ឌទី១ នៃមាត្រា៥៨៥ ក្រមរដ្ឋប្បវេណី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រឹមអត្រាចាប់ពី១០ (ដប់) ភាគរយទៅ ៣០ (សាមសិប) ភាគរយក្នុងមួយឆ្នាំ"* ។

យោងប្រកាសលេខ ១២៨ កយ.ប្រក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ របស់ប្រសួងយុត្តិធម៌ ស្តីពី អត្រាការប្រាក់ដែលត្រូវបានកម្រិត ប្រការ១ បានចែងថា៖ *"អត្រាការប្រាក់ដែលត្រូវបានកម្រិតដែលបានកំណត់ក្នុងកថាខណ្ឌទី១ នៃមាត្រា១៧ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ត្រូវបានកំណត់មិនឲ្យលើសពី ១៨% (ដប់ប្រាំបីភាគរយ) ក្នុងមួយឆ្នាំ"* ។ ដូច្នេះគប្បីតុលាការសម្រេចទទួលស្គាល់អត្រាការប្រាក់ចំនួន **១០.៥០% (ដប់ចុចហាសិបភាគរយ) ក្នុងមួយឆ្នាំ** ស្របតាមការទាមទាររបស់ដើមចោទ ។

៦/ ចំពោះប្រាក់ពិន័យ (ប្រាក់សំណងការខូចខាតដោយសារការយឺតយ៉ាវ) **២៤% (ម្ភៃបួនភាគរយ)** ក្នុងមួយឆ្នាំ សម្រាប់កិច្ចសន្យាខ្ចីប្រាក់នេះ គឺជាការ ព្រមព្រៀងអំពីការកំណត់ជាមុននូវចំនួននៃសំណង ក្នុងករណីមិនអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យាខ្ចីប្រាក់ដែលមាន កម្មវត្ថុជាប្រាក់ ហើយតាមរយៈនេះ យោងប្រកាសលេខ ១២៨ កយ.ប្រក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ របស់ប្រសួងយុត្តិធម៌ ស្តីពី អត្រាការប្រាក់ដែលត្រូវបានកម្រិត ប្រការ២ បានចែងថា៖ *"អត្រាការប្រាក់ ដែលបានព្រមព្រៀងជាមុនក្នុងការសងសំណងក្នុងកិច្ចសន្យាខ្ចីបរិភោគ ដែលមានកម្មវត្ថុជាប្រាក់ ដែលបានកំណត់ក្នុងកថាខណ្ឌទី៣ នៃមាត្រា១៧ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ត្រូវបានកំណត់មិនឲ្យលើសពីចំនួន ១,៥ ដង (**១,៥X១៨=២៧% ក្នុង១ឆ្នាំ**) នៃអត្រាការប្រាក់ដែលបានកំណត់ក្នុងប្រការ១ខាងលើ"* ។ ដូច្នេះគប្បីតុលាការ សម្រេចទទួលស្គាល់ប្រាក់ពិន័យ (ប្រាក់សំណងការខូចខាតដោយសារការយឺតយ៉ាវ) **២៤% (ម្ភៃបួនភាគរយ)** ក្នុងមួយឆ្នាំ ស្របតាមការទាមទាររបស់ដើមចោទ។

៧/ ការដែលដើមចោទ ប្តឹងទាមទារប្រាក់ថ្លៃសេវាពិគ្រោះផ្លូវច្បាប់ និងការចំណាយផ្សេងៗលើនីតិវិធី ចំនួន USD ៥,០០០ (ប្រាំពាន់ដុល្លារអាមេរិក) តុលាការពិនិត្យឃើញថាការប្តឹងផ្តល់នេះ គឺពិតជាធ្វើអោយដើមចោទមានការខាតបង់លើថ្លៃសេវាកម្មច្បាប់ ការខាតបង់ពេលវេលា និងការចំណាយផ្សេងៗ ពិតប្រាកដមែន ប៉ុន្តែដើមចោទពុំបានផ្តល់កស្តុតាងបញ្ជាក់ច្បាស់អំពីទំហំនៃការខូចខាតនោះទេ ហេតុដូច្នេះតុលាការគប្បី ពិចារណាសម្រេចតាមគោលការណ៍សមធម៌ ដោយគិតពិចារណាអំពីកាល:ទេស:ជុំវិញផ្សេងៗ ។

៨- តាមការស្នើសុំរបស់ភាគីដើមចោទ ដែលបានស្នើសុំឲ្យតុលាការប្រកាសថា **សាលក្រមនេះអាចអនុវត្តជាបណ្តោះអាសន្នបាន** គឺជាការត្រឹមត្រូវ ដោយហេតុថាសាលក្រមនេះ ជាសាលក្រមដែលសម្រេចអំពីការទាមទារសិទ្ធិលើទ្រព្យសម្បត្តិ និងមានភាពចាំបាច់សម្រាប់ដើមចោទជា **ធនាគារ** ដែលចាំបាច់ត្រូវតែមានលំហូរសាច់ប្រាក់ល្អប្រសើរ និងមិនអាចទុកឱ្យមានបំណុលខូច ឬ បំណុលដែលមិនអាចទារបានក្នុងរយៈពេលយូរដូចនេះទេ។ ម្យ៉ាងវិញទៀត សហចុងចម្លើយបានទទួលស្គាល់ចំពោះការទាមទារ របស់ដើមចោទលើប្រាក់ដើម វាគឺជាសក្ខីកម្មមួយ ដែលបញ្ជាក់ច្បាស់លាស់ អំពីអត្ថិភាពនៃសិទ្ធិទាមទាររបស់ដើមចោទ លើចំនួនទឹកប្រាក់ដើម ដែលនឹងពុំមានការប្រែប្រួលឡើយ ដូច្នេះគប្បីតុលាការ ប្រកាសថា សាលក្រមនេះអាចអនុវត្តជាបណ្តោះអាសន្នបានលើប្រាក់ដើម ការប្រាក់ និងប្រាក់ពិន័យ ដោយពុំចាំបាច់ឲ្យដាក់ប្រាតិភោគ ស្របតាមមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

កំណត់សំគាល់៖ សាលក្រមនេះជារឿងក្តីដាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ

៩- ផ្អែកតាមបញ្ញត្តិមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី តុលាការត្រូវសម្រេចអំពី បន្ទុកនៃប្រាក់ប្រដាប់ក្តីហើយ ដោយហេតុថាការប្តឹងទាមទារប្រាក់នេះ កើតចេញពីកំហុសរបស់ចុងចម្លើយដែលបានបំពានក្នុងការអនុវត្តកាតព្វកិច្ចនោះ គប្បីសម្រេចអំពីប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ ។

សេចក្តីសម្រេចបញ្ចប់ៈ

ក- បង្គាប់ឱ្យសហចុងចម្លើយ ឈ្មោះ ច១ , ឈ្មោះ ច២ និងឈ្មោះ ច៣ រួមគ្នាសងដោយកាតព្វកិច្ចសាមគ្គី ទៅឱ្យដើមចោទ ដ នូវប្រាក់ដូចខាងក្រោមៈ

១. ប្រាក់ដើមចំនួន USD ៦៦,០៧៨.៥៨ (ហុកសិបប្រាំមួយពាន់ចិតសិបប្រាំបីដុល្លារអាមេរិក និងហាសិបប្រាំបីសេន)។

២. អាត្រាការប្រាក់ចំនួន ១០.៥០% ក្នុងមួយឆ្នាំ លើប្រាក់ដើម គិតចាប់ពីថ្ងៃទី១៧ ខែតុលា ឆ្នាំ ២០១៨ រហូតដល់ថ្ងៃអនុវត្តការសងប្រាក់គ្រប់ចំនួន ។

៣. ប្រាក់ពិន័យ (ប្រាក់សំណងការខូចខាតដោយសារការយឺតយ៉ាវ) ចំនួន ២៤% ក្នុងមួយឆ្នាំ លើចំនួនទឹកប្រាក់ដែលខកខានមិនបានសង សមាមាត្រទៅនឹងចំនួនថ្ងៃដែលខកខានសង គិតចាប់ពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ ២០១៨ រហូតដល់ថ្ងៃអនុវត្តការសងប្រាក់គ្រប់ចំនួន ។

ខ- បង្គាប់ឱ្យសហចុងចម្លើយ ឈ្មោះ ច១ , ឈ្មោះ ច២ និងឈ្មោះ ច៣ រួមគ្នាសងដោយកាតព្វកិច្ចសាមគ្គី នូវប្រាក់សោហ៊ុយរខាតបង់ពេលវេលា និង សេវាពិគ្រោះផ្លូវច្បាប់ ចំនួន USD ៣.០០០ (បីពាន់) ដុល្លារអាមេរិក ទៅឱ្យដើមចោទ ដ ។

ការទាមទារលើសពីនេះសម្រេចច្រានចោល ។

គ- សាលក្រមនេះអាចអនុវត្តជាបណ្តោះអាសន្នបាន នៅត្រង់ចំណុច "ក" នៃសេចក្តីសម្រេចបញ្ចប់នេះ ។

ឃ- ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

សាលក្រមនេះ បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩ និងប្រកាសសាលក្រមជាសាធារណៈ នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩ វេលាម៉ោង៨និង៣០នាទីព្រឹក ចំពោះមុខដើមចោទ និងសហចុងចម្លើយ ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

ថ្ងៃស្រុក៧រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
ក្រចេះ ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩

ចៅក្រម

មាត្តលេខា និងត្រា ញ្ជ្រិល ប៊ុនលី

បានឃើញ	**សាលក្រមនេះបានផ្ទតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
ចៅក្រម	ថ្ងៃ.....ខែ.....ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
	ក្រចេះ ថ្ងៃទី.....ខែ.....ឆ្នាំ២០១៩
	ក្រឡាបញ្ជី

ញ្ជ្រិល ប៊ុនលី

កំណត់សំគាល់ៈ សាលក្រមនេះជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ